# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៧ សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការសម្របសម្រួលការងាររៀបចំប្រព័ន្ធទិដ្ឋាការអេឡិចត្រូនិច "E-visa"

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## ស ម្រេ ច

**ប្រការ១** : បង្កើតគណៈកម្មការសម្របសម្រួលការងាររៀបចំប្រព័ន្ធទិដ្ឋាការអេឡិចត្រូនិច "E-visa" ដែលមានសមាសភាព ដូចខាងក្រោម:

| | | |
|---|---|---|
| ១- ឯកឧត្តម **ឡុង វិសាលោ** | រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| ២- លោកវរសេនីយ៍ឯក **ពុំ វិតវុទ្ធា** | អនុប្រធាននាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ | អនុប្រធាន |

៣-ឯកឧត្តម **ហង់ ជួនណារ៉ុន** អគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៤-លោក **ខូន តាំងឈាង** អគ្គលេខាធិការរង អាជ្ញាធរជាតិទទួលបន្ទុកអភិវឌ្ឍន៍បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា ទីស្តីការគណៈរដ្ឋមន្ត្រី ។ សមាជិក

**ប្រការ២ :** គណៈកម្មការនេះមានតួនាទី និងភារកិច្ចដូចខាងក្រោម :

១-សម្របសម្រួលការងាររៀបចំហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍប្រព័ន្ធ E-visa

២-ត្រួតពិនិត្យ និងសម្របសម្រួលក្នុងការគ្រប់គ្រងបញ្ជីខ្មៅឱ្យមានប្រសិទ្ធភាព ដោយភ្ជាប់ប្រព័ន្ធ E-visa ជាមួយប្រព័ន្ធព័ត៌មានអន្តរជាតិ ស្តីពីភេរវកម្មអន្តរជាតិ

៣-ត្រួតពិនិត្យដំណើរការអនុវត្តប្រព័ន្ធ E-visa និងតាមដានការគ្រប់គ្រងចំណូលពីប្រព័ន្ធ E-visa នេះ

៤-សម្របសម្រួល និងដោះស្រាយបញ្ហាបច្ចេកទេសក្នុងការគ្រប់គ្រង និងដំណើរការប្រព័ន្ធ E-visa និងបញ្ហាអសកម្មផ្សេងៗទៀត ។

**ប្រការ៣ :** គណៈកម្មការនេះមានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំ តំណាងក្រសួង-ស្ថាប័នផ្សេងទៀត ដែលមិនស្ថិតក្នុងសមាជិកគណៈកម្មការដើម្បីចូលរួមប្រជុំពិភាក្សា និងសហការបំពេញការងារតាមការជាក់ស្តែង ។

**ប្រការ៤ :** សមាជិកទាំងអស់នៃគណៈកម្មការនេះត្រូវអញ្ជើញចូលរួមប្រជុំ និងធ្វើការងារតាមសេចក្តីអញ្ជើញ និងការណែនាំរបស់ប្រធាន ។

**ប្រការ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងប្រការមួយ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

*កន្លែងទទួល :*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចចែងក្នុងប្រការ ៥*
- *ឯកសារ-កាលប្បវត្តិ* ✓